**របាយការណ៍សង្ខេបស្តីពីការងារប្រយុទ្ធទប់ស្កាត់ការរាលដាល និងស្ថានភាព**
**មេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា**
**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**ក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩**

ថ្ងៃអាទិត្យ ៥កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
សាលសន្និសីទចតុមុខ, ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩

- សូមគោរព ឯកឧត្តមនាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន** ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី២ នៃរដ្ឋសភា អនុប្រធានកាកបាទក្រហមកម្ពុជា និងជាប្រធានក្រុមការងារតស៊ូរជនធ្វើមថ្នាក់ជាតិ
- ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ តំណាងអង្គទូតនានាប្រចាំព្រះរាជាណាចក្រកម្ពុជា
- លោកជំទាវ Pauline Tamesis អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រីមកពីអង្គការសង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ បណ្តាញប្រជាជនគន្លឹះ ភ្ញៀវជាតិ និងអន្តរជាតិ ព្រមទាំងក្មួយៗទាំងអស់ជាទីរាប់អាន!

ថ្ងៃនេះ ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយស និងបីតិសោមនស្សរីករាយក្រៃលែង ដែលបានរៀបចំទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ឆ្នាំ២០១៩ ដ៏មហោឡារិក នាពេលនេះ។

ជាបឋម ខ្ញុំសូមអនុញ្ញាតសម្តែងនូវគារវកិច្ចដ៏ឧត្តុង្គឧត្តម ចំពោះ ឯកឧត្តមនាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន** ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានឆ្លៀតពេលដ៏មមាញឹក និងមានតម្លៃ អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់នាឱកាសនេះ។ ការណ៍នេះបង្ហាញនូវការយកចិត្តទុកដាក់ខ្ពស់ និងការប្តេជ្ញាចិត្តខាងនយោបាយដ៏មោះមុត នៃថ្នាក់ដឹកនាំកំពូលរាជរដ្ឋាភិបាលចំពោះកាតព្វកិច្ចប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជា ដែលជាកត្តាគន្លឹះកំណត់នូវភាពជោគជ័យដ៏ត្រចះត្រចង់ជាបន្តបន្ទាប់ នាំមកនូវការទទួលស្គាល់ និងការកោតសរសើរពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ។ យើងខ្ញុំទាំងអស់គ្នា

ជាថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន សមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ព្រមទាំងដៃគូការងារទាំងអស់ ត្រៀមលក្ខណៈជាស្រេចទទួលយកជាថ្មីម្តងទៀត នូវអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមនាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី** ទៅអនុវត្ត ដើម្បីធ្វើឱ្យសម្រេចដោយជោគជ័យ នូវការលុបបំបាត់ការឆ្លងរីករាលដាលមេរោគអេដស៍ នាឆ្នាំ២០២៥ ខាងមុខ។

ជារៀងរាល់ឆ្នាំ ក្នុងនាមរាជរដ្ឋាភិបាល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍តែងរៀបចំពិធីប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ថ្ងៃទី១ ខែធ្នូ ជាទៀងទាត់ ក្នុងបំណងបង្ហាញការប្តេជ្ញាចិត្តដ៏មុតស្រួចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ រំលឹកនូវការផ្តល់ការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងរំលឹកនូវសោកនាដកម្មនៃអ្នកស្លាប់ដោយសារជំងឺអេដស៍ ព្រមទាំងក្រើនរំលឹកដល់ប្រជាពលរដ្ឋទូទាំងប្រទេស ឱ្យចងចាំជានិច្ចពីគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ ដើម្បីទាំងអស់គ្នាឈានទៅលុបបំបាត់ការឆ្លងរីករាលដាលមេរោគអេដស៍ រួមចំណែកក្នុងការអភិវឌ្ឍរបស់មនុស្សជាតិ។

ក្នុងរយៈពេលជាងពីរទសវត្សរ៍នៃបេសកកម្មប្រយុទ្ធនឹងជំងឺអេដស៍របស់ខ្លួន កម្ពុជាតែងអនុវត្តស្របតាមគោលនយោបាយ និងគោលដៅយុទ្ធសាស្ត្ររបស់អង្គការសហប្រជាជាតិ ជាអាទិ៍គោលនយោបាយសូន្យបីឆ្នាំ២០២០ (គ្មានការឆ្លងមេរោគអេដស៍ថ្មី គ្មានការមាក់ងាយនិងរើសអើង និងគ្មានការស្លាប់ដោយសារជំងឺអេដស៍) និងគោលដៅ ៩០ ៩០ ៩០ នៅឆ្នាំ២០២០ (ដែលមានន័យថា ៩០% នៃអ្នកផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ៩០% នៃអ្នកដែលដឹងស្ថានភាពផ្ទុកមេរោគអេដស៍បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង ៩០% នៃអ្នកដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទទួលបានប្រសិទ្ធភាពខ្ពស់ ក្នុងការកាត់បន្ថយចំនួនមេរោគអេដស៍នៅក្នុងខ្លួន)។ គោលនយោបាយ និងគោលដៅយុទ្ធសាស្ត្រនេះត្រូវបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រជាតិលើកទី៥ នៃការឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ២០១៩-២០២៣ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា។

លើសពីការតាំងចិត្តរបស់ពិភពលោក ក្រោយពីការសម្រេចបានគោលដៅ ៩០ ៩០ ៩០ នៅឆ្នាំ ២០១៧ មុនកាលកំណត់ ដែលប្រកាសទទួលស្គាល់ដោយអង្គការ UNAIDS កម្ពុជាបានបន្តប្តេជ្ញាចិត្តប្រកបដោយមហិច្ឆតាក្នុងការលុបបំបាត់ការឆ្លងរីករាលដាលមេរោគអេដស៍នៅឆ្នាំ២០២៥ គឺមុនគោលដៅពិភពលោក៥ឆ្នាំ ដែលក្នុងនោះយើងត្រូវធ្វើឱ្យ សម្រេចគោលដៅ ៩៥ ៩៥ ៩៥ នៅឆ្នាំ២០២៥ និងមិនទុកនរណាម្នាក់ចោលដោយមិនបានទទួលការយកចិត្តទុកដាក់ឡើយ ក្នុងក្តីសង្ឃឹមដ៏មុតមាំកសាងមនុស្សជាតិជំនាន់ថ្មីមួយដែលគ្មានមេរោគអេដស៍។

ភាពជោគជ័យលើការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅប្រទេសកម្ពុជា គឺធ្វើឡើងដោយមានការចូលរួមទាំងអស់គ្នាតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** គឺ "**ទាំងអស់គ្នាចូលរួមជាចរន្តជាតិមួយ ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគ**

**អេដស៍ និងជំងឺអេដស៍**” ដែលមកដល់ពេលនេះ ជាលទ្ធផល ប្រទេសកម្ពុជាទទួលបាននូវជោគជ័យជាទីមោទនៈ រួមមាន៖

- នៅឆ្នាំ២០០៦ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា បានទទួលគោរម្យងារពីអង្គការសហប្រជាជាតិ ជា “ឥស្សរជនឆ្នើមថ្នាក់ជាតិ នៃវេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ី-ប៉ាស៊ីហ្វិកឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា”
- នៅឆ្នាំ២០០៩ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ក៏បានទទួលនូវ “ពានរង្វាន់វេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ីប៉ា-ស៊ីហ្វិកស្តីពីមេរោគអេដស៍ ជំងឺអេដស៍ និងការអភិវឌ្ឍ” ពីអង្គការសហប្រជាជាតិ ជាថ្មីទៀត។
- ឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានទទួលពានរង្វាន់ពីអង្គការសហប្រជាជាតិក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សលើការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- នៅឆ្នាំ២០១៧ អង្គការ UNAIDS បានប្រកាសទទួលស្គាល់ប្រទេសកម្ពុជាក្នុងចំណោមប្រទេសចំនួន៧ ទៀតនៅក្នុងពិភពលោក (រួមមាន ចក្រភពអង់គ្លេស អ៊ីស្លង់ ដាណឺម៉ាក ស៊ុយអ៊ែត សឹង្ហបុរី និងបុតស្វាណា) ថាជាប្រទេសដែលអាចសម្រេចបាននូវគោលដៅ ៩០ ៩០ ៩០ មុនកាលកំណត់។

**ឯកឧត្តម លោកជំទាវ និងអង្គពិធីទាំងមូល!**

នាឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមអនុញ្ញាត ជម្រាបជូន **ឯកឧត្តមនាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី** ព្រមទាំងអង្គពិធីទាំងមូល នូវស្ថានភាពនៃការរីករាលដាលនិងសមិទ្ធផលនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍មួយចំនួនដូចតទៅ៖

- អ្នកឆ្លងថ្មីមានការថយចុះប្រមាណជា៦២% ចាប់ពីឆ្នាំ២០១០ មកដល់ឆ្នាំ២០១៨ ដែលតាមការប៉ាន់ប្រមាណអ្នកឆ្លងថ្មីប្រមាណពីជាង២.៣០០នាក់ នៅឆ្នាំ២០១០ មកនៅត្រឹមប្រមាណ៨៨០នាក់ នាឆ្នាំ២០១៨ កន្លងទៅនេះ។
- អ្នកស្លាប់ដោយសារមេរោគអេដស៍ ក៏មានការថយចុះប្រមាណជា ៤៨% ផងដែរ ចាប់ពីឆ្នាំ២០១០មកដល់ឆ្នាំ២០១៨ ដែលតាមការប៉ាន់ស្មានអ្នកស្លាប់ប្រមាណជាង ២.៥០០នាក់ នៅឆ្នាំ២០១០ មកនៅត្រឹមប្រមាណជាង ១.៣០០នាក់នាឆ្នាំ២០១៨ កន្លងទៅនេះ។
- នៅឆ្នាំ២០១៨ កន្លងទៅនេះការធ្វើតេស្តមេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះ មានការកើនឡើងពី១៦,៨%ឆ្នាំ២០០៧ ដល់ទៅ៩៧% នាឆ្នាំ២០១៧ ។
- ស្ត្រីមានផ្ទៃពោះមានផ្ទុកមេរោគអេដស៍ បានទទួលថ្នាំប្រឆាំងមេរោគអេដស៍មានការកើនឡើងពី ១១% នៅឆ្នាំ២០០៧ ដល់៩៤% នៅឆ្នាំ២០១៧ ។
- ការរាយការណ៍ពីការមាក់ងាយ និងរើសអើងពីខាងក្រៅមានការធ្លាក់ចុះ ជាពិសេសការបដិសេធមិនផ្តល់ការងារប្រមាណពី៤៦%នៅឆ្នាំ២០១០ មកនៅតែប្រមាណ២% នៅឆ្នាំ២០១៩ និងការបំពានជាពាក្យសំដីប្រមាណពី១៤%នៅឆ្នាំ២០១០ មកនៅតែប្រមាណ២% នៅឆ្នាំ២០១៩ ។ ប៉ុន្តែការមាក់ងាយ និងរើសអើងដោយខ្លួនឯង ជាពិសេសអារម្មណ៍

ខ្វះសៀវភៅ នៅតែជាបញ្ហាគួរឱ្យព្រួយបារម្ភនៅឡើយដោយមានអត្រា៧១,៥% នៅឆ្នាំ ២០១០ មកនៅ ៦២,៧% នៅឆ្នាំ២០១៩ ។

- អ្នកបម្រើសេវាកម្សាន្តសប្បាយមានចំនួនប្រមាណ ៣៤.០០០នាក់ មានអត្រាផ្ទុកមេរោគអេដស៍ ថយចុះពី ១៤% នៅឆ្នាំ២០០០ មកត្រឹម ៣,២% នៅឆ្នាំ២០១៦។

**ឯកឧត្តម លោកជំទាវ និងអង្គពិធីទាំងមូល!**

ជាយុទ្ធសាស្ត្រការឆ្លើយតបខាងមុខរបស់យើង គឺផ្តោតលើការខិតខំស្វែងរកករណីអ្នកផ្ទុកមេរោគអេសដស៍ដែលនៅសល់ចំនួនប្រមាណ១២.០០០នាក់ បញ្ជូនទៅសេវាព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ហើយថែរក្សាអ្នកជំងឺទាំងឡាយក្នុងសេវាថែទាំព្យាបាលឱ្យជាប់លាប់ ដើម្បីបង្ការការកើតឡើងនូវភាពស៊ាំទៅនឹងឱសថ។ ដើម្បីសម្រេចជំហាននេះ ទន្ទឹមនឹងការពង្រឹងប្រព័ន្ធសុខាភិបាលឱ្យទទួលភារកិច្ចថែទាំព្យាបាលប្រកបដោយប្រសិទ្ធភាពខ្ពស់ យើងត្រូវរួមគ្នាធ្វើកិច្ចការជាច្រើនទៀត ដើម្បីកាត់បន្ថយរាល់របាំងរារាំងពលរដ្ឋពីការទទួលបានសេវាបង្ការការឆ្លង និងរារាំងអ្នកផ្ទុកមេរោគអេដស៍ពីការទទួលបានសេវាថែទាំព្យាបាល។ ក្នុងគោលបំណងឱ្យការធ្វើអន្តរាគមន៍ទាំងឡាយនេះ បានទទួលជោគជ័យ និងធានាចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ ជំងឺអេដស៍ក្នុងរយៈពេលវែង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់មួយចំនួនជាអាទិ៍ៈ

- សហការជាមួយក្រសួងមហាផ្ទៃ ដើម្បីបង្កើតនិយាមបែបបទដាក់សំណុំសកម្មភាពឆ្លើយតបមេរោគអេដស៍ចូលក្នុងផែនការអភិវឌ្ឍឃុំសង្កាត់ ផែនការវិនិយោគឃុំសង្កាត់ និងគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដើម្បីឃុំសង្កាត់មានលទ្ធភាពជួយស្វែងរកករណីផ្ទុកមេរោគអេដស៍ បញ្ជូនទៅរកសេវាថែទាំព្យាបាល សម្របសម្រួលបង្កបរិយាកាសអំណោយផល និងផ្តល់ការគាំទ្រសង្គមដល់គ្រួសារអ្នកជំងឺអេដស៍ក្រីក្រ។
- សហការជាមួយក្រសួងផែនការ ផ្តល់អត្តសញ្ញាណកម្មគ្រួសារក្រីក្រជូនដល់អ្នកផ្ទុកមេរោគអេដស៍ក្រីក្រ ដើម្បីទទួលបានប្រយោជន៍បន្ថែមក្នុងការថែទាំសុខភាព និងការគាំទ្រសង្គម។
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងឡាយ បន្តជំរុញការផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធ និងបង្កើនការអប់រំបង្ការការឆ្លងមេរោគអេដស៍ ក្នុងចំណោមក្រុមប្រជាជនគន្លឹះ ក្រុមយុវវ័យ បុគ្គលិកសហគ្រាស គ្រឹះស្ថាននានា ពលរដ្ឋចំណាកស្រុក និងវិស័យទេសចរណ៍។
- ធានាឱ្យបាននូវចីរភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ដោយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ធ្វើការបញ្ជ្រាប និងបញ្ចូលបញ្ហាអេដស៍ទៅក្នុងផែនការរួមរបស់ក្រសួង ស្ថាប័ន ខេត្ត រាជធានី ស្រុក ខណ្ឌ និងឃុំ សង្កាត់។
- បន្តធានានិងកំណត់ចំពោះប្រជាជនប្រឈមមុខ និងអ្នកផ្ទុកមេរោគអេដស៍ជាអាទិភាពដែលត្រូវផ្តល់សិទ្ធិ និងឱកាសទទួលបានសេវាសុខភាព និងសេវាសង្គមស្មើមុខដូចជាប្រជាជនទូទៅ នៅក្នុងសង្គម។

កិច្ចអន្តរាគមន៍ទាំងនេះ ទាមទារនូវថវិកាគាំទ្រ ក្នុងពេលដែលហិរញ្ញប្បទានក្រៅប្រទេសបន្តធ្លាក់ចុះ។ យោងតាមការសិក្សាពីតម្រូវការវិនិយោគឆ្លើយតបនឹងមេរោគអេដស៍ (Investment case) យើងត្រូវការថវិកាប្រមាណ២០លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំរហូតដល់ឆ្នាំ២០២០ ឬ ប្រមាណ៦០លានដុល្លារ នៅពេលដែលយើងទទួលបានថវិកាពីមូលនិធិសកល ត្រឹមតែ៤១,៦លានដុល្លារសហរដ្ឋអាមេរិកសម្រាប់បីឆ្នាំ ពី២០១៨ ដល់២០២០ ដោយយើងមិនទាន់មានសញ្ញាពីការគាំទ្រក្រោយឆ្នាំ២០២០ នៅឡើយ។ ហេតុនេះ យើងគ្មានជម្រើសអ្វីក្រៅពីត្រៀមលក្ខណៈធ្វើជាម្ចាស់នៃអន្តរាគមន៍នេះទាំងស្រុងនាពេលអនាគតនោះឡើយ។

ជាក់ស្តែង ចាប់តាំងពីឆ្នាំ២០១៥ រាជរដ្ឋាភិបាលបានចូលរួមនូវថវិកាជាតិចំនួន១,៥លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ ហើយតាំងចិត្តបន្តចូលរួមក្នុងបរិមាណដូចគ្នារហូតដល់ឆ្នាំ២០២០ ព្រមទាំងយល់ព្រមទទួលយកបន្ទុកចំណាយលើបុគ្គលិកកិច្ចសន្យា ក្នុងទំហំទឹកប្រាក់ចំនួនប្រមាណ១លានដុល្លារសហរដ្ឋអាមេរិកថែមទៀតសម្រាប់ឆ្នាំខាងមុខ។ ជាបណ្តើរៗ យើងជឿថាថវិកាជាតិនឹងចូលមកជំនួសជំនួយក្រៅប្រទេសទាំងស្រុង។

ក្នុងជំនួបកិច្ចប្រជុំក្រុមប្រឹក្សាមូលនិធិសកលលើកទី៤២ ដែលប្រព្រឹត្តទៅនៅទីក្រុងហ្សឺណែវ ប្រទេសស្វីសពីថ្ងៃទី១២ដល់១៥ ខែវិច្ឆិកា ដោយមានការចូលរួមពីតំណាងមកពីតំបន់នានានៅជុំវិញសកលលោក សមាសធាតុគន្លឹះ៣ដែលជាសមិទ្ធផលក្នុងការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលកម្ពុជាបាន និងកំពុងធ្វើឱ្យសម្រេចជោគជ័យមកទល់ពេលនេះ រួមមាន : ១) មគ្គុទ្ទេសក៍ភាព និងភាពជាម្ចាស់ ២) ភាពជាដៃគូ និង ៣) ការវិនិយោគ។ ក្នុងមគ្គុទ្ទេសក៍ភាព និងភាពជាម្ចាស់ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដឹកនាំយន្តការសម្របសម្រួល និងឆ្លើយតបជាពហុវិស័យ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញនូវវិធានការ៦ចំណុច ដើម្បីធានាចីរភាពក្នុងការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍កាលពីខែកុម្ភៈ ឆ្នាំ២០១៩នេះផងដែរ។ បន្ថែមលើនេះ ពាក់ព័ន្ធនឹងកម្មវិធីមូលនិធិសកល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានទទួលតួនាទីជាអ្នកទទួលជំនួយផ្ទាល់ ចាប់តាំងពីខែមេសា ឆ្នាំ២០១៨ កន្លងមកនេះ។

ចំពោះ ដៃគូអភិវឌ្ឍន៍ ដូចជា UNAIDS, UNDP, អង្គការសុខភាពពិភពលោក, អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលធ្វើការរួមគ្នាដោយត្រួតពិនិត្យរួមគ្នានូវវឌ្ឍនភាពនៃការអនុវត្តកម្មវិធីអេដស៍ ជាពិសេសការចូលរួមដ៏មានតម្លៃ និងមិនចេះនឿយហត់របស់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ដែល **សម្តេច** តែងតែផ្តល់ការគាំទ្រជាប់ជាប្រចាំ ទាំងថវិកាសម្ភារ និងស្មារតី ជួយដល់ប្រជាពលរដ្ឋក្រីក្រ អ្នករងគ្រោះទូទៅ ដោយឡែកប្រជាពលរដ្ឋដែលកំពុងរងគ្រោះដោយផ្ទាល់ និងដោយប្រយោលពីការរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ នៅទូទាំងប្រទេស។

ជាមួយគ្នានេះ នៅក្នុងការវិនិយោគចាប់ពីឆ្នាំ២០១៥ រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់ថវិកាចំនួន១ ទៅ១,៥លានដុល្លារ ក្នុងមួយឆ្នាំ ដែលជាថវិកាបដិភាគក្នុងការទិញឱសថ

ប្រឆាំងនឹងមេរោគអេដស៍ និងថវិកាចំនួនប្រមាណ៨០០.០០០ដុល្លារ ក្នុងមួយឆ្នាំក៏ត្រូវបានផ្តល់ជូនបុគ្គលិកជាប់កិច្ចសន្យាដែលធ្វើការក្នុងគម្រោងជំនួយមូលនិធិសកលផងដែរ។

មុននឹងបញ្ចប់ ខ្ញុំសូមការអនុញ្ញាត **ឯកឧត្តមនាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី** និងអង្គពិធី ធ្វើការអំពាវនាវនូវការគាំទ្របន្ថែមទៀតពី រាជរដ្ឋាភិបាល កាកបាទក្រហមកម្ពុជា និងដៃគូអភិវឌ្ឍន៍ទាំងអស់ បន្តជួយបង្កើនការគាំទ្រហិរញ្ញវត្ថុ សម្ភារ បច្ចេកទេស ដើម្បីឱ្យយើងមានលទ្ធភាពរក្សាចីរភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិលើកទី៥ ឆ្ពោះទៅលុបបំបាត់ការឆ្លង រីករាលដាលមេរោគអេដស៍ នៅឆ្នាំ ២០២៥ ដោយជោគជ័យ និងសូមអំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ចូលរួមប្តេជ្ញាចិត្តដ៏មោះមុតជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដូចខាងក្រោម៖

- សូមប្រជាពលរដ្ឋទាំងអស់ សស្រាក់សស្រាំចូលរួមបង្ការទប់ស្កាត់ការឆ្លងមេរោគអេដស៍ ឆាប់ទៅធ្វើតេស្តឈាម ឆាប់ទៅទទួលការព្យាបាល ឈានឆ្ពោះទៅបញ្ចប់អេដស៍។
- សូមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអតិថិជនទាំងអស់ ប្រើប្រាស់ស្រោមអនាម័យឱ្យ បានជាប់លាប់១០០% រៀងរាល់ពេលមានទំនាក់ទំនងរួមភេទ។
- សូមបុរសចូលរួមទទួលខុសត្រូវយ៉ាងសកម្មចំពោះខ្លួនផ្ទាល់ ភរិយា ដៃគូ និងកូនចៅរបស់ខ្លួន ចៀសផុតពីសោកនាដកម្មបង្កដោយការឆ្លងមេរោគអេដស៍។
- សូមក្មួយៗយុវវ័យទាំងអស់កុំឆាប់ប្រឡូកនឹងការរួមភេទ ហើយត្រូវចាកចេញឱ្យឆ្ងាយពីគ្រឿងញៀនដែលជាកត្តាប្រឈមខ្ពស់នឹងការឆ្លងមេរោគអេដស៍។
- សូមស្ត្រីមានផ្ទៃពោះទាំងអស់ ត្រូវទៅទទួលការធ្វើតេស្តឈាមរកមេរោគអេដស៍ ហើយបើមានតេស្តវិជ្ជមាន ត្រូវប្រញាប់ស្វែងរកសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យបានឆាប់រហ័ស នៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យរដ្ឋនានា នៅទូទាំងប្រទេស។
- សូមអ្នកដែលមានការប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍ ត្រូវប្រញាប់ស្វែងរកការធ្វើតេស្តឈាមរកមេរោគអេដស៍ឱ្យបានឆាប់រហ័សនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋ ឬបណ្តាញអង្គការសង្គមស៊ីវិល ដើម្បីឈានទៅទទួលការថែទាំព្យាបាលទាន់ពេលវេលា។
- សូមអ្នកដឹងថាមានផ្ទុកមេរោគអេដស៍ទាំងអស់ ត្រូវប្រញាប់ទៅទទួលការថែទាំព្យាបាលឱ្យបានឆាប់រហ័ស និងគោរពវេជ្ជបញ្ជាឱ្យបានខ្ជាប់ខ្ជួន ដើម្បីការពារការស្រុតចុះសុខភាព និង ចៀសវាងការកើតនូវភាពស៊ាំរបស់មេរោគអេដស៍ទៅនឹងឱសថប្រឆាំងមេរោគអេដស៍ ដែលជាមូលហេតុនៃមរណភាពដោយសារជំងឺអេដស៍ និងសូមកុំបន្តចម្លងមេរោគអេដស៍ដល់អ្នកដទៃទៀត។
- សូមយើងទាំងអស់គ្នា ចាត់ទុកអ្នកផ្ទុកមេរោគអេដស៍ជាជនរងគ្រោះ ជាសមាជិកគ្រួសារ សហគមន៍ និងសង្គមយើង ដែលធ្លាប់ និងនៅតែរួមចំណែកក្នុងផលិតភាពនៃសេដ្ឋកិច្ចជាតិយើង ហើយត្រូវចូលរួមលុបបំបាត់រាល់ទម្រង់នៃការរើសអើង និងមាក់ងាយដល់ពួកគាត់ឱ្យបានជាដាច់ខាត និងត្រូវផ្តល់ការគាំទ្រគ្រប់លទ្ធភាព។
- រាល់ការឆ្លើយតបនឹងមេរោគអេដស៍ និងអ្នកជំងឺអេដស៍ទាំងអស់ត្រូវតែឈរលើគោលការណ៍សមធម៌ សមភាពយេនឌ័រ និងសិទ្ធិមនុស្ស។

ជាថ្មីម្តងទៀត តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ដែលតែងតែផ្តល់ការគាំទ្រជានយោបាយ និងយុទ្ធសាស្ត្រ ដល់ការឆ្លើយតបនឹងការរីករាលដាលមេរោគអេដស៍ ជាពិសេសការបង្កើននូវថវិកាជាតិជារៀងរាល់ឆ្នាំ ដើម្បីឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានលទ្ធភាពពង្រីកសកម្មភាពការងារជាយុទ្ធសាស្ត្ររបស់ខ្លួនបានជាប្រចាំ និងសូមអំពាវនាវដល់អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល វិស័យឯកជន បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ បន្តចូលរួមជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ថែមទៀត តាមគ្រប់រូបភាព ជាកម្លាំងកាយ ប្រាជ្ញាស្មារតី សម្ភារ និងថវិកាដើម្បីពង្រីកអន្តរាគមន៍ប្រយុទ្ធនឹងជំងឺអេដស៍ ឈានទៅសម្រេចបាននូវអត្រាគ្របដណ្តប់លើភូមិសាស្ត្រ លើក្រុមគោលដៅឱ្យបាន ១០០%។

មុននឹងបញ្ចប់ ខ្ញុំសូមអនុញ្ញាត សម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ អង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍ មូលនិធិសកល សង្គមស៊ីវិល ផ្នែកឯកជន សិល្បៈករសិល្បៈការិនីដែលមានតំណាងជាអគ្គរដ្ឋទូតសុឆន្ទៈសម្រាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍ បណ្តាញអ្នកផ្ទុកមេរោគអេដស៍ បណ្តាញក្រុមប្រជាជនគន្លឹះ និងក្មួយៗយុវជនទាំងអស់ ព្រមទាំងប្រជាពលរដ្ឋទូទៅដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការសម្រេចបាន នូវសមិទ្ធផលជាទីមោទនៈជូនប្រទេសកម្ពុជានាពេលនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យបវរមហាប្រសើរជូន **ឯកឧត្តមនាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី** សូមប្រកបដោយសុខភាពល្អបរិបូរណ៍ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីបន្តចូលរួមក្នុងការដឹកនាំនាវាកម្ពុជាឱ្យចាកផុតពីគ្រោះគំរាមកំហែង ដោយសារមេរោគអេដស៍ និងជំងឺអេដស៍ ក្រោមមាគ៌ាដឹកនាំប្រកបដោយគតិបណ្ឌិត សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងដៃគូអភិវឌ្ឍ តំណាងអង្គទូត ភ្ញៀវជាតិ អន្តរជាតិ និងក្មួយៗទាំងអស់ សូមប្រកបនូវពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមថ្លែងនូវការកោតសរសើរ ដល់គណៈកម្មការរៀបចំអង្គពិធី ដែលបានរៀបចំទិវានេះប្រព្រឹត្តទៅដោយរលូន និងប្រកបដោយជោគជ័យ។

*សូមអរគុណ !*